# របាយការណ៍ប្រចាំខែវិច្ឆិកា ឆ្នាំ ២០១៥ របស់មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តឧត្តរមានជ័យ

## ១. សេចក្តីផ្តើម

ខេត្តឧត្តរមានជ័យស្ថិតនៅទិសឧត្តរនៃព្រះរាជាណាចក្រកម្ពុជា មានចម្ងាយប្រមាណជា ៤៤១ គីឡូម៉ែត្រពីរាជធានីភ្នំពេញ មានផ្ទៃដីសរុបចំនួន ៦ ៦៣១,៧២ គីឡូម៉ែត្រក្រឡា ។ ខេត្តនេះមានព្រំប្រទល់ខាងកើតជាប់នឹងខេត្តព្រះវិហារ ខាងលិចជាប់នឹងខេត្តបន្ទាយមានជ័យ ខាងត្បូងជាប់នឹងខេត្តសៀមរាប និងខាងជើងប្រវែង ២២៥ គីឡូម៉ែត្រជាប់នឹងខេត្តស៊ីសាកេត ខេត្តបុរីរ៉ាំ និងខេត្តសុរិន្ទ្រ ប្រទេសថៃ និងមានស្រុកចំនួន ០៤ និងក្រុង ០១ គឺស្រុកអន្លង់វែង ស្រុកត្រពាំងប្រាសាទ ស្រុកចុងកាល់ ស្រុកបន្ទាយអំពិល និងក្រុងសំរោង។

## ២. ស្ថានភាពរបស់មន្ទីរ

### ២.១ ការងាររដ្ឋបាល និងបុគ្គលិក

មន្ទីរអភិវឌ្ឍន៍ជនបទខេត្តឧត្តរមានជ័យ ដឹកនាំដោយប្រធានមន្ទីរ ០១ រូប និងអមដោយអនុប្រធានមន្ទីរចំនួន ០២រូប រួមមានបុគ្គលិកសរុបចំនួន ៣៣នាក់ ក្នុងនោះនៅកម្រិតរដ្ឋបាលថ្នាក់មន្ទីរមានការិយាល័យជំនាញចំនួន ០៨ និងថ្នាក់ស្រុក ០៥ ។

### ២.២ កិច្ចប្រជុំផ្សេងៗ និងទំនាក់ទំនងសាធារណៈ

- ថ្ងៃទី ២៦ ខែតុលា ថ្នាក់ដឹកនាំមន្ទីរ ចូលរួមប្រជុំរៀបចំបុណ្យអុំទូកឆ្នាំ ២០១៥ នៅសាលប្រជុំធំសាលាខេត្តឧត្តរមានជ័យ
- ថ្ងៃទី ២៧ ខែតុលា ថ្នាក់ដឹកនាំមន្ទីរចូលរួមប្រជុំគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ប្រចាំខែតុលា ឆ្នាំ ២០១៥ នៅសាលប្រជុំ គ.ប្រ សាលាខេត្ត
- ថ្ងៃទី ០១ ខែវិច្ឆិកា មន្ត្រីការិយាល័យរដ្ឋបាល ០១ រូប ចូលរួមអបអរសាទរពិធីបើកបវេសនកាលឆ្នាំសិក្សា ២០១៥-២០១៦ នៅសាលាអនុវិទ្យាល័យសំរោង
- ថ្ងៃទី ០៣ ខែវិច្ឆិកា មន្ត្រីចំនួន ០១ រូប ចូលរួមពិធីសម្ពោធអាគារសម្ភពមន្ទីរពេទ្យបង្អែកអន្លង់វែងនៅស្រុកអន្លង់វែង
- ថ្ងៃទី ០៣ ខែវិច្ឆិកា ថ្នាក់ដឹកនាំមន្ទីរចូលរួមប្រជុំបូកសរុបលទ្ធផលការងារចុះវាស់វែងដីជូនប្រជាពលរដ្ឋ នៅចំណុចអូរអំបិល ភូមិអូតាម៉េង ឃុំអន្លង់វែង ស្រុកអន្លង់វែង នៅសាលប្រជុំលេខ ១២ សាលាខេត្តឧត្តរមានជ័យ
- ថ្ងៃទី ០៤ ខែវិច្ឆិកា លោកប្រធានមន្ទីរចូលរួមចែកប័ណ្ណកម្មសិទ្ធជូនប្រជាពលរដ្ឋ នៅក្រុងសំរោង ក្រោមអធិបតីភាព **ឯកឧត្តម ស ថាវី** អភិបាលនៃគណៈអភិបាលខេត្ត នៅសាលាក្រុងសំរោង
- ថ្ងៃទី ០៤ ខែវិច្ឆិកា មន្ត្រីចំនួន ០១ រូប ចូលរួមកិច្ចប្រជុំគណៈកម្មការហិរញ្ញប្បទានសុខាភិបាលប្រចាំត្រីមាសទី ៣ ឆ្នាំ ២០១៥ នៅសាលប្រជុំសុខាភិបាលខេត្ត
- ថ្ងៃទី០៥-០៨ ខែវិច្ឆិកា លោកប្រធានមន្ទីរចូលរួមពិធីតាំងពិពណ៌ផលិតផលកម្ពុជា-ថៃ ពិធីក្រុងពាលី និងពិធីអុំទូកប្រចាំឆ្នាំ២០១៥ នៅសួនច្បារមាត់បឹងស្មោរ មុខសាលាខេត្ត
- ថ្ងៃទី ១០ ខែវិច្ឆិកា លោកប្រធានមន្ទីរចូលរួមកិច្ចប្រជុំសាមញ្ញលើកទី ១៨ របស់ក្រុមប្រឹក្សាខេត្ត

ឆ្នាំទី ២ អាណត្តិទី ២ នៅសាលប្រជុំតំសាលាខេត្ត

- ថ្ងៃទី ១១ ខែវិច្ឆិកា មន្ត្រីការិយាល័យរដ្ឋបាលចំនួន ០២ រូប ចូលរួមសិក្ខាសាលាស្តីពីលទ្ធផលសិក្សាពីតម្រូវការសម្រាប់ការអភិវឌ្ឍសមត្ថភាពមន្ទីរអភិវឌ្ឍន៍ជនបទ នៅសាលប្រជុំជាន់ទី ៣ ទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- ថ្ងៃទី ១២ ខែវិច្ឆិកា លោកប្រធានមន្ទីរ និងមន្ត្រីចំនួន ០២ រូប ចូលរួមប្រារព្ធទិវាជាតិលើកកម្ពស់អនាម័យជនបទលើកទី ៦ ក្រោមអធិបតីភាព **ឯកឧត្តម ជា សុផារ៉ា** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ នៅឃុំត្រពាំងសាលាខាងលិច ស្រុកបន្ទាយមាស ខេត្តកំពត
- ថ្ងៃទី ១៦ ខែវិច្ឆិកា លោកប្រធានមន្ទីរ និងមន្ត្រីចំនួន ១៥ រូប រៀបចំពិធីប្រារព្ធទិវាជាតិលើកកម្ពស់អនាម័យជនបទលើកទី ៦ នៅសាលាស្រុកបន្ទាយអំពិល និង
- ថ្ងៃទី ១៨ ខែវិច្ឆិកា មន្ត្រីចំនួន ០១ រូប ចូលរួមប្រជុំ Pro TWG-H ប្រចាំខែតុលា ឆ្នាំ ២០១៥ នៅសាលប្រជុំមន្ទីរសុខាភិបាលខេត្តឧត្តរមានជ័យ។

## ៣. លទ្ធផលសម្រេចបានតាមវិស័យ

### ៣.១ ការងារផ្លូវជនបទ

- ចុះត្រួតពិនិត្យខ្សែផ្លូវលិចលង់ និងហូរច្រោះដោយទឹកជំនន់ នៅភូមិប្រាសាទបី ដល់ភូមិវល្លិយាវ ឃុំបេង ស្រុកបន្ទាយអំពិល ប្រវែង ១០,១០០ គីឡូម៉ែត្រ សម្រាប់ផែនការជួសជុល ឆ្នាំ ២០១៦
- ចុះត្រួតពិនិត្យខ្សែផ្លូវពីវត្តបេងទៅភូមិសឹង្ហ (56)ប្រវែង ៤.៨០០ ម៉ែត្រ ក្នុងផែនការជួសជុលបន្ទាន់ឆ្នាំ ២០១៦ នៅឃុំបេង ស្រុកបន្ទាយអំពិល
- ចុះត្រួតពិនិត្យខ្សែផ្លូវក្នុងផែនការជួសជុលបន្ទាន់ឆ្នាំ ២០១៦ នៅឃុំពង្រ ស្រុកចុងកាល់ ប្រវែងសរុប ១០ គីឡូម៉ែត្រ
- ចុះត្រួតពិនិត្យការសាងសង់ផ្លូវជួសជុលបន្ទាន់ចំនួន ០៤ ខ្សែ នៅឃុំចុងកាល់ ស្រុកចុងកាល់ ប្រវែងសរុប ៧ ៣០០ ម៉ែត្រ ជាលទ្ធផលរួចរាល់ជាស្ថាពរ ១០០% និង
- ចុះធ្វើបច្ចុប្បន្នភាព និងប្រមូលទិន្នន័យផ្លូវជនបទក្នុងស្រុក/ក្រុងចំនួន ០២ គឺក្រុងសំរោង ស្រុកត្រពាំងប្រាសាទ និងស្រុកអន្លង់វែង សរុបបានប្រវែង ១២៤,៤០ គីឡូម៉ែត្រ ។

### ៣.២ ការងារថែទាំសុខភាពជនបទ

មន្ត្រីការិយាល័យថែទាំសុខភាពចូលរួមកិច្ចប្រជុំស្តីពីការធ្វើពង្រៀងគំរូរបាយការណ៍បូកសរុបលទ្ធផលការងារឆ្នាំ ២០១១-២០១៥ ក្រោមហិរញ្ញប្បទានអង្គការ Unicef នៅសាលប្រជុំជាន់ទី ៣ ទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ។

### ៣.៣ ការអភិវឌ្ឍន៍ភូមិដែនដីសខាងជើង និងខាងលិចប្រទេស

#### ៣.៣.១ ការងារសាងសង់ផ្ទះ

ភូមិតាមាន់សែនជ័យ÷ ផ្ទះចំនួន ៣៧ ខ្នង បានបញ្ចប់រួចរាល់ ១០០%។

#### ៣.៣.២ ការងារសាងសង់ផ្លូវ (អនុវត្តដោយនាយកដ្ឋានផ្លូវលំជនបទ)

- ភូមិតាមាន់សែនជ័យ÷ ផ្លូវក្រាលគ្រួសក្រហម ០១ ខ្សែ មាន ០៥ កំណាត់ ប្រវែង ៨.៤០០ ម៉ែត្រ ទទឹង ០៥ ម៉ែត្រ សំណង់សិល្បការគ្រប់ប្រភេទ ២៧ កន្លែង ចាក់ដីស ៩០% សាងសង់លូប្រអប់បាន ៦០% និងលូមូលបាន ៧៥% សម្រេចបានលទ្ធផល ៩០%
- ភូមិប្រាសាទក្រហមសែនជ័យ÷ ផ្លូវក្រាលគ្រួសក្រហមមាន ០៧ កំណាត់ ប្រវែងសរុប ១២.០០០ ម៉ែត្រ ទទឹង ៥ ម៉ែត្រ (ផ្លូវមេប្រវែង ៤.៥០០ ម៉ែត្រ ) និងលូមូលចំនួន ២០ កន្លែង សម្រេចបានលទ្ធផល ៩០% និង
- ភូមិពពេលសែនជ័យ÷ ផ្លូវក្រាលគ្រួសក្រហម ០១ ខ្សែ ៣.៦០០ ម៉ែត្រ ចាក់ដីសបាន ១០០% ក្រាលគ្រួសក្រហមបាន ៩០% សាងសង់សំណង់សិល្បការបាន ៥០%។

### ៣.៤ ការិយាល័យស្រុក/ក្រុង

- ប្រធានការិយាល័យក្រុងសំរោងចូលរួមប្រជុំ គ.ក.ស ប្រចាំខែតុលា ឆ្នាំ ២០១៥ នៅសាលាក្រុងសំរោង
- ប្រធានការិយាល័យក្រុងសំរោងចូលរួមប្រជុំសាមញ្ញលើកទី ១៧ របស់ក្រុមប្រឹក្សាក្រុងសំរោង នៅសាលាក្រុងសំរោង
- ប្រធានការិយាល័យក្រុងសំរោង ចូលរួមអបអរក្នុងពិធីបើកបវេសនកាលសាលាបឋមសិក្សាសំរោង ឆ្នាំសិក្សាថ្មី ២០១៥- ២០១៦ នៅសាលាបឋមសិក្សាសំរោង និង
- ប្រធានការិយាល័យស្រុកចុងកាល់ចូលរួមពិធីការដ្ឋានជួសជុលផ្លូវបន្ទាន់នៅភូមិថ្មី ឃុំចុងកាល់ ស្រុកចុងកាល់។

## ៤. ទិសដៅការងារបន្ត

- ចុះត្រួតពិនិត្យ និងសិក្សាខ្សែផ្លូវជួសជុលបន្ទាន់ និងសាងសង់ថ្មីទូទាំងខេត្ត សម្រាប់ការអនុវត្តក្នុងឆ្នាំ ២០១៦
- បន្តចុះប្រមូលទិន្នន័យខ្សែផ្លូវ និងធ្វើបច្ចុប្បន្នភាពនៅស្រុកអន្លង់វែង និងស្រុកត្រពាំងប្រាសាទ
- រៀបចំសម្របសម្រួលកិច្ចប្រជុំត្រីមាសថ្នាក់ឃុំ ស្តីពីកម្មវិធីទឹកស្អាត និងអនាម័យ
- បន្តរៀបចំកម្មវិធីអប់រំផ្សព្វផ្សាយការលើកកម្ពស់អនាម័យនៅជនបទតាមរយៈវិទ្យុ និង
- ចុះត្រួតពិនិត្យ និងជំរុញការសាងសង់បង្គន់អនាម័យនៅតាមគ្រួសារ។